ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 02 / 05 / 2018
ម៉ោង (Time/Heure): 10 : 30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

Confidential / Confidentiel

ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៨

Declassified to Public
25 January 2019

**ជូនចំពោះ៖** លោក Isaac Endeley
ប្រធានអង្គភាពគាំពារការការពារក្តី
លោក Victor Koppe
សហមេធាវីអន្តរជាតិការពារក្តីលោក នួន ជា

**ពី៖** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន៖** លោក/លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង, ភាគីទាំងអស់ក្នុងសំណុំរឿង ០០២

**កម្មវត្ថុ៖** ឋានៈរបស់សហមេធាវីអន្តរជាតិការពារក្តីលោក នួន ជា ក្នុងសំណុំរឿង ០០២/០២

១. តាមកម្មវត្ថុខាងលើ កាលពីថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១៨ អង្គជំនុំជម្រះសាលាដំបូងបានទទួលអនុស្សរណៈមួយ (ឯកសារ E378/8/1) ពីប្រធានអង្គភាពគាំពារការការពារក្តី ដោយបញ្ជាក់ថា លោក Victor Koppe មិនមែនជាសមាជិកគណៈមេធាវីនៃទីក្រុងអាំស្ទែរដាំ (ABA) ឬ ជាសមាជិកគណៈមេធាវីបរទេសណាមួយផ្សេងទៀត ចាប់តាំងពីថ្ងៃទី០១ ខែ មករា ឆ្នាំ ២០១៦។ អនុស្សរណៈនេះបានលើកឡើងទៀតថា លោក Koppe បានបញ្ជាក់ថា គាត់បានបញ្ចប់សមាជិកភាពរបស់គាត់នៅគណៈមេធាវីនៃទីក្រុងអាំស្ទែរដាំ ដោយសារគាត់ពុំបានទទួលការណែនាំថាការបន្តសមាជិកភាពនៅគណៈមេធាវីបរទេស គឺជាបុរេលក្ខខណ្ឌសម្រាប់បន្តសមាជិកភាពនៅគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា (BAKC) ឡើយ។ កិច្ចសន្យាផ្តល់សេវាផ្នែកច្បាប់ដែលគាត់បានចុះហត្ថលេខាជាមួយអង្គការសហប្រជាជាតិ មិនបានចែងថា គាត់ចាំបាច់ត្រូវតែនៅបន្តជាសមាជិកនៃគណៈមេធាវីបរទេស បន្ទាប់ពីគាត់ត្រូវបានចុះបញ្ជីនៅគណៈមេធាវីកម្ពុជានោះឡើយ។ ជាមួយគ្នានេះផង

ដែរ សមាជិកភាពរបស់គាត់នៅគណៈមេធាវីបរទេសលែងមានការចាំបាច់ទៀតហើយ បន្ទាប់ពីបានទទួលការអនុញ្ញាតដោយគណៈមេធាវីកម្ពុជា និងបានចុះឈ្មោះនៅក្នុងបញ្ជីឈ្មោះមេធាវីអន្តរ-ជាតិ ដែលត្រូវរក្សាដោយអង្គភាពគាំពារការការពារក្តី។ អង្គជំនុំជម្រះក៏បានកត់សម្គាល់អំពីការចង្អុលបង្ហាញរបស់លោក Koppe ដែលថា គាត់យល់ព្រមបន្តសមាជិកភាពរបស់គាត់នៅគណៈមេធាវីនៃទីក្រុងអាំស្ទែរដាំជាថ្មីឡើងវិញ ប្រសិនបើអង្គជំនុំជម្រះតម្រូវដូច្នេះ។

២. អង្គជំនុំជម្រះកត់សម្គាល់ថា សហមេធាវីអន្តរជាតិទាំងអស់ ដែលប្រកបវិជ្ជាជីវៈនៅ អ.វ.ត.ក. ចាំបាច់ត្រូវតែរក្សាឋានៈរបស់ខ្លួនក្នុងពេលបច្ចុប្បន្ន ជាសមាជិកគណៈមេធាវីដែលមានកិត្តិនាមល្អ និងត្រូវបានទទួលស្គាល់នៅក្នុងប្រទេសណាមួយដែលជាសមាជិកអង្គការសហប្រជាជាតិ ក្រៅពីប្រទេសកម្ពុជា។ ផ្ទុយពីការលើកឡើងរបស់លោក Koppe លក្ខខណ្ឌនេះមិនត្រឹមតែតម្រូវឱ្យអនុវត្តនៅក្នុងដំណាក់កាលនៃការចុះឈ្មោះនៅក្នុងបញ្ជីឈ្មោះមេធាវី ដែលមានសម្បទាតាមផ្លូវច្បាប់នោះទេ។ លក្ខខណ្ឌនេះត្រូវបានឆ្លុះបញ្ចាំងនៅក្នុងការវាយតម្លៃជារួមនៃក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក. ទាក់ទងនឹងសម្បទាផ្លូវច្បាប់របស់មេធាវីអន្តរជាតិ ដែលប្រកបវិជ្ជាជីវៈនៅ អ.វ.ត.ក.។

៣. វិធាន ១១(២)(ឃ)(២) នៃវិធានផ្ទៃក្នុង តម្រូវឱ្យអង្គភាពគាំពារការការពារក្តីរក្សាបញ្ជីឈ្មោះ "មេធាវីបរទេសដែលទទួលការអនុញ្ញាតដោយគណៈមេធាវីរបស់រដ្ឋណាមួយ ដែលជាសមាជិករបស់អង្គការសហប្រជាជាតិ ហើយដែលបានចុះឈ្មោះនៅគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងឆ្លើយតបទៅនឹងលក្ខណៈវិនិច្ឆ័យរបស់អង្គភាពគាំពារការការពារក្តី (...) ដូចមានចែងក្នុងបទបញ្ជារដ្ឋបាល"។ ពុំមានចំណុចណាមួយនៅក្នុងបទប្បញ្ញត្តិនេះ ឬ បទប្បញ្ញត្តិផ្សេងទៀតលើកឡើងថា លក្ខខណ្ឌតម្រូវនៃសមាជិកភាពនៅក្នុងគណៈមេធាវីបរទេសលែងមានភាពចាំបាច់បន្ទាប់ពីមេធាវីអន្តរជាតិបានទទួលការអនុញ្ញាតចុះបញ្ជីនោះទេ។ ផ្ទុយទៅវិញ អង្គជំនុំជម្រះកត់សម្គាល់ថា លក្ខខណ្ឌតម្រូវ "រក្សា" បញ្ជីឈ្មោះមេធាវី បង្ហាញអំពីកាតព្វកិច្ចដែលត្រូវធ្វើបន្តចំពោះអង្គភាពគាំពារការការពារក្តី ហើយគ្រប់លក្ខណៈវិនិច្ឆ័យទាំងអស់ត្រូវតែបន្តបំពេញ។ ហេតុដូច្នេះបញ្ជីឈ្មោះមេធាវីមិនមែនត្រូវបានរក្សាតែក្នុងពេលចុះបញ្ជីឈ្មោះមេធាវីណាម្នាក់នោះទេ ប៉ុន្តែវាត្រូវរក្សាបន្តទៀត។ ស្រដៀងគ្នានេះផងដែរ វិធាន ១១(៤)(គ)(១) នៃវិធានផ្ទៃក្នុង ចែងថាលក្ខណៈវិនិច្ឆ័យក្នុង "ការបញ្ចូល" អ្នកដាក់ពាក្យសុំជាជនបរទេសទៅក្នុងបញ្ជីដែលចែងក្នុងវិធាន ១១(២)(ឃ)(២) នៃវិធានផ្ទៃក្នុង រួមមាន ក្នុងពេលបច្ចុប្បន្ន ជាសមាជិកគណៈមេធាវីដែលមានកិត្តិនាមល្អ និងត្រូវបានទទួលស្គាល់នៅក្នុងប្រទេសដែលជាសមាជិកអង្គការសហប្រជាជាតិ។ ពាក្យ "ការ

បញ្ចូល” សំដៅដល់ដំណើរការជាបន្ត ដោយគ្របដណ្ដប់មិនត្រឹមតែនៅពេលចាប់ផ្ដើមចុះបញ្ជីនោះទេ ប៉ុន្តែវាក៏សំដៅដល់អំឡុងពេលវេលាបន្ទាប់មកទៀត នៅក្នុងអំឡុងពេលដែលមេធាវីអន្តរជាតិស្ថិតក្នុងបញ្ជីនោះ។

៤. បទបញ្ជារដ្ឋបាលរបស់អង្គភាពគាំពារការការពារក្ដី ស៊ីសង្វាក់ជាមួយនឹងការយល់ឃើញនេះ។ មាត្រា ១.៧ បញ្ជាក់ថា “បេក្ខជនដែលត្រូវបញ្ចូលឈ្មោះទៅក្នុងបញ្ជី អាចត្រូវបានដកចេញពីបញ្ជីវិញនៅពេល៖ ... ២. ឈប់ឆ្លើយតបទៅតាមលក្ខខណ្ឌ ដូចមានចែងនៅក្នុងវិធានផ្ទៃក្នុង និងបទ-បញ្ជារដ្ឋបាលនៃ អ.វ.ត.ក. ...”។ សមាជិកភាពនៅក្នុងគណៈមេធាវីបរទេសគឺជាគុណវុឌ្ឍិមួយដែលត្រូវបានកំណត់នៅក្នុងវិធានផ្ទៃក្នុង និងបទបញ្ជារដ្ឋបាលរបស់អង្គភាពគាំពារការការពារក្ដី (មាត្រា ២.២)។ ហេតុដូច្នេះ នត្ថិភាពសមាជិកភាពនៅក្នុងពេលណាមួយនោះ អាចនាំឱ្យមានការដកមេធាវីរូបនោះចេញពីបញ្ជីឈ្មោះមេធាវីដែលមានសម្បទាផ្លូវច្បាប់ក្នុងការប្រកបវិជ្ជាជីវៈ។ មាត្រា ៤.៣ ចែងថា “ដើម្បីទទួលបានការអនុញ្ញាត [ដោយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា] តំណាងឱ្យកូនក្ដីនៅចំពោះមុខអង្គជំនុំជម្រះ មេធាវីបរទេស ក្នុងពេលបច្ចុប្បន្ន ត្រូវតែជាមេធាវីដែលមានកិត្តិនាមល្អ និងត្រូវបានទទួលស្គាល់នៅក្នុងប្រទេសដែលជាសមាជិកអង្គការសហប្រជាជាតិ”។ ការប្រកបវិជ្ជាជីវៈនៅ អ.វ.ត.ក. គឺជាដំណើរការជាបន្តបន្ទាប់ មិនមែនកើតឡើងតែក្នុងពេលតែម្ដងនោះទេ។ ដើម្បីទទួលបានការអនុញ្ញាតឱ្យបន្តការប្រកបវិជ្ជាជីវៈ មេធាវីបរទេសត្រូវបន្តរក្សាសមាជិកភាពរបស់ខ្លួននៅក្នុងគណៈមេធាវីបរទេស។

៥. កិច្ចសន្យាផ្ដល់សេវាផ្នែកច្បាប់រវាងលោក Koppe និងអង្គភាពគាំពារការការពារក្ដីក៏គាំទ្រផងដែរដល់ការយល់ឃើញ ដែលថាការចុះឈ្មោះសហមេធាវីអន្តរជាតិនៅគណៈមេធាវីកម្ពុជាតែមួយគត់គឺមិនគ្រប់គ្រាន់នោះទេ។ ដូចបានចែងយ៉ាងច្បាស់នៅក្នុងកថាខណ្ឌ ៦.២ ក្របខណ្ឌគតិយុត្តិសម្រាប់កិច្ចសន្យានោះបញ្ចូលទាំង “ក្រមសីលធម៌វិជ្ជាជីវៈរបស់គណៈមេធាវី ដែលសហមេធាវីចុះកិច្ចសន្យាស្ថិតនៅជាសមាជិក និងក្រមសីលធម៌វិជ្ជាជីវៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា”។ ដោយក្រមសីលធម៌វិជ្ជាជីវៈទីពីរសំដៅជាក់លាក់ដល់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដូចនេះ ក្រមសីលធម៌ទីមួយគឺសំដៅដល់គណៈមេធាវីរបស់ប្រទេសមួយផ្សេងទៀត។ ពាក្យពេចន៍ដែលបានប្រើប្រាស់នៅក្នុងបទប្បញ្ញត្តិនេះ បានបង្ហាញយ៉ាងច្បាស់ថា ផ្នែកទាំងនេះគឺជាលក្ខខណ្ឌរួមបញ្ចូលគ្នា មិនមែនជាលក្ខខណ្ឌដាច់ដោយឡែកឡើយ។

៦. លើសពីនេះ មានការបង្ហាញយ៉ាងច្បាស់លាស់ថែមទៀតដោយក្រុមខណ្ឌតតិយុត្តិថា មេធាវីអន្តរជាតិអាចត្រូវបានតម្រូវឱ្យទទួលខុសត្រូវចំពោះឥរិយាបថរបស់ខ្លួន នៅពេលប្រកបវិជ្ជាជីវៈនៅ អ.វ.ត.ក.។ ពាក់ព័ន្ធនឹងចំណុចនេះ វិធាន ៣៨(២) នៃវិធានផ្ទៃក្នុង អនុញ្ញាតឱ្យអង្គជំនុំជម្រះបញ្ជូនករណីពាក់ព័ន្ធនឹងកំហុសវិជ្ជាជីវៈរបស់មេធាវីទៅកាន់ "អង្គភាពមានសមត្ថកិច្ច" ហើយកថាខណ្ឌ ៦.៩ នៃកិច្ចសន្យាផ្តល់សេវាផ្នែកច្បាប់ចែងថា មុនពេលចាប់ផ្តើមកិច្ចសន្យា "សហមេធាវីចុះកិច្ចសន្យាត្រូវផ្តល់ជូនអង្គភាពគាំពារការការពារក្តីនូវឯកសារនានាដូចខាងក្រោម ... ខ. សំណៅដើម ១ ច្បាប់ និងសំណៅបកប្រែជាភាសាអង់គ្លេស ឬ ភាសាបារាំង ១ ច្បាប់ នៃអត្ថបទទាំងមូលនៃក្រមសីលធម៌វិជ្ជាជីវៈរបស់គណៈមេធាវី ដែលសហមេធាវីចុះកិច្ចសន្យាជាសមាជិក រួមជាមួយព័ត៌មានលម្អិតរបស់បុគ្គល ដែលទទួលខុសត្រូវបញ្ហាវិន័យ នៅក្នុងសមាគមវិជ្ជាជីវៈរបស់សហមេធាវីចុះកិច្ចសន្យា"។ នៅពេលអនុវត្តជាក់ស្តែង អង្គជំនុំជម្រះកត់សម្គាល់ថា លក្ខខណ្ឌដំបូងចំពោះមេធាវីអន្តរ-ជាតិ ដែលត្រូវផ្តល់ដល់អង្គភាពគាំពារការការពារក្តីនូវក្រមសីលធម៌វិជ្ជាជីវៈរបស់គណៈមេធាវីបរទេសដែលមេធាវីនោះជាសមាជិកនឹងពុំមានប្រយោជន៍ទេ ប្រសិនបើមេធាវីបរទេសនោះក្រោយមកទៀតអាចដកខ្លួនចេញពីគណៈមេធាវី ដែលបានពិភាក្សាខាងលើ ដោយពុំមានទទួលនូវផលវិបាកអ្វីនោះ។

៧. ពាក់ព័ន្ធនឹងគណៈមេធាវីកម្ពុជា អង្គជំនុំជម្រះកត់សម្គាល់ថា លោក Koppe បានលើកឡើងថា បន្ទាប់ពីបានចុះឈ្មោះក្នុងបញ្ជីឈ្មោះមេធាវីបរទេសនៃគណៈមេធាវីកម្ពុជា សមាជិកភាពនៅក្នុងគណៈមេធាវីបរទេស មិនជាប់ពាក់ព័ន្ធនឹងសមាជិកភាពរបស់គាត់នៅក្នុងគណៈមេធាវីកម្ពុជានោះទេ ដោយហេតុថា គណៈមេធាវីកម្ពុជាមិនបានណែនាំឱ្យបានច្បាស់លាស់អំពីលក្ខខណ្ឌបន្ត ហើយមិនបានឱ្យគាត់បង្ហាញភ័ស្តុតាងពាក់ព័ន្ធការបន្តសមាជិកភាព។ អង្គជំនុំជម្រះយល់ឃើញថា ទោះបីជាអង្គជំនុំជម្រះទទួលយកភាពជាតំណាងរបស់លោក Koppe នៅ អ.វ.ត.ក. ក៏ដោយ ប៉ុន្តែនេះមិនអាចបញ្ជាក់អំពីការដកចេញនូវលក្ខខណ្ឌតម្រូវក្នុងការបន្តសមាជិកភាពរបស់គាត់ នៅក្នុងគណៈមេធាវីបរទេសនោះទេ។ វាជាការសមស្របដែលថាគណៈមេធាវីកម្ពុជារំពឹងថា ខ្លួននឹងទទួលបានការជូនដំណឹងពីមេធាវីអន្តរជាតិ អំពីការប្រែប្រួលឋានៈរបស់ពួកគេ ក្រោយពេលចុះបញ្ជី។ ជាងនេះទៅទៀត មាត្រា ៥ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី បានភ្ជាប់សិទ្ធិរបស់មេធាវីបរទេសក្នុងការប្រកបវិជ្ជាជីវៈនៅ អ.វ.ត.ក. ជាមួយនឹងលក្ខខណ្ឌជាសមាជិកភាពរបស់គណៈ-មេធាវីបរទេស។ ដូចបានកត់សម្គាល់ខាងលើ "ប្រកបវិជ្ជាជីវៈ" គឺជាទស្សនាទានជាបន្ត ដែលបង្ហាញថា លក្ខខណ្ឌជាមូលដ្ឋានគឺជាកាតព្វកិច្ចដែលត្រូវធ្វើបន្ត។

៨. ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា មានលក្ខខណ្ឌដែលអត្ថិភាព និងចាំបាច់ដែលថា សហមេធាវីអន្តរជាតិ ក្នុងពេលបច្ចុប្បន្ន ត្រូវតែជាសមាជិកនៃគណៈមេធាវីដែលមានកិត្តិនាមល្អ និងត្រូវបានទទួលស្គាល់នៅក្នុងប្រទេស ដែលជាសមាជិកអង្គការសហប្រជាជាតិ ក្រៅពីប្រទេសកម្ពុជា ហើយថា លោក Koppe បានរំលោភបំពានទៅលើលក្ខខណ្ឌនេះ ចាប់តាំងពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១៦ មក។

៩. អាស្រ័យហេតុនេះ អង្គជំនុំជម្រះជូនដំណឹងឱ្យលោក Koppe ស្នើសុំចុះឈ្មោះគាត់ជាបន្ទាន់នៅក្នុងបញ្ជីគណៈមេធាវីណាមួយ ដែលត្រូវបានទទួលស្គាល់នៅក្នុងប្រទេសដែលជាសមាជិកអង្គការសហប្រជាជាតិ ក្រៅពីប្រទេសកម្ពុជា ឱ្យបានត្រឹមថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០១៨។ ស្របពេលជាមួយគ្នានេះ អង្គជំនុំជម្រះស្នើលោក Koppe បំពេញនិយ័តកម្មជាមួយនឹងគណៈមេធាវីបរទេសទាក់ទងស្ថានភាពរបស់គាត់ ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១៦ មក។ ជាជម្រើសម្យ៉ាងទៀត អង្គជំនុំជម្រះស្នើឱ្យលោក Koppe ដាក់សារណាពាក់ព័ន្ធនឹងកម្មវត្ថុនេះ មិនឱ្យហួសពីថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០១៨ ហើយបន្ទាប់ពីនោះ អង្គជំនុំជម្រះអាចនឹងចេញដីកាសម្រេចពាក់ព័ន្ធនឹងបញ្ហានេះ។